# លី ហួរ អ៊ិនសួរេន ម.ក
## LY HOUR INSURANCE PLC

ទំនុកចិត្ត សុវត្ថិភាព



# ព័ត៌មានអំពីក្រុមហ៊ុន

# តារាងមាតិកា


I. សារលិខិតរបស់ប្រធានក្រុមប្រឹក្សាភិបាល

II. ក្រុមហ៊ុនមេ ( លី ហួរ គ្រុប ) និងបុត្រសម្ព័ន្ធ

III. អំពីក្រុមហ៊ុនយើងខ្ញុំ

IV. ចក្ខុវិស័យ និងបេសកកម្ម

V. ផលិតផល និង សេវាកម្ម

VI. ក្រុមហ៊ុនធានារ៉ាប់រងបន្ត

VII. ការដោះស្រាយសំណង និង ព័ត៌មានទូទៅ



## សារលិខិតរបស់ប្រធានក្រុមប្រឹក្សាភិបាល

ប្រទេសកម្ពុជាស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍ ជាប្រទេសមួយសំបូរដោយធនធានធម្មជាតិ និងសម្បត្តិបេតិកភណ្ឌជាតិយ៉ាងច្រើន ។ អស់រយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាត្រូវប្រែក្លាយខ្លួនពីប្រទេសដែលមានវិបត្តិទៅជាប្រទេសដែលមានសន្តិភាព និងបង្កើតឱកាសវិនិយោគមានលក្ខណៈអនុគ្រោះដល់វិនិយោគិនជាតិ និងអន្តរជាតិ ដោយអនុវត្តគោលនយោបាយទីផ្សារសេរីនិងបើកចំហ ។ ស្របជាមួយនឹងស្ថិរភាពនយោបាយ និងសន្តិសុខសង្គម សេដ្ឋកិច្ចជាតិបន្តកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ហើយត្រូវបានព្យាករណ៍ប្រកបដោយសុទ្ធិនិយមថានឹងបន្តកើនឡើងនៅឆ្នាំខាងមុខទៀត ។

ដោយមានបរិយាកាសអំណោយផលល្អ និងសក្តានុពលជាច្រើននៅក្នុងប្រទេស **ក្រុមហ៊ុន លី ហួរ គ្រុប** បានវិនិយោគទុនក្នុងពហុវិស័យរួមមាន ការអភិវឌ្ឍលំនៅឋាន និងសំណង់ វិស័យហិរញ្ញវត្ថុ និង ដំណាំកសិឧស្សាហកម្មបៃតងជាដើម ។ ដំណើរការវិនិយោគនិងអាជីវកម្មតាំងពីឆ្នាំ១៩៨៦ មកដល់សព្វថ្ងៃ ក្រុមហ៊ុនទទួលបានភាពជោគជ័យជាបន្តបន្ទាប់ ដោយការអនុវត្តគោលការណ៍សុចរិតភាព ស្មោះត្រង់ តម្លាភាព និងការចាត់ទុកអតិថិជនទាំងអស់ជាដៃគូអាជីវកម្មរយៈពេលវែងរបស់យើង ។

ទន្ទឹមនឹងភាពជោគជ័យក្នុងអាជីវកម្ម គឺត្រូវការជាចាំបាច់នូវការការពារ ដល់ការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាលើគ្រប់វិស័យ ដើម្បីរក្សាស្ថិរភាពអាជីវកម្មរបស់ខ្លួន និងដៃគូអាជីវកម្មប្រកបដោយនិរន្តភាព ។ ដោយយល់ឃើញពីភាពប្រថុយប្រថាន និងហានិភ័យទាំងឡាយ **ក្រុមហ៊ុន លី ហួរ គ្រុប** បានសម្រេចបង្កើតក្រុមហ៊ុនធានារ៉ាប់រងទូទៅឡើង ក្នុងគោលបំណងផ្តល់ការការពារផ្នែកហិរញ្ញវត្ថុជូនអតិថិជន ដៃគូអាជីវកម្ម និងអតិថិជនដែលតែងតែផ្តល់ទំនុកចិត្ត និងជឿជាក់មកលើ ក្រុមហ៊ុនបុត្រសម្ព័ន្ធ របស់ **លី ហួរ គ្រុប** ។

**ក្រុមហ៊ុន លី ហួរ អ៊ិនសួរេន ម.ក** ជាបុត្រសម្ព័ន្ធទី ៨ ដែលត្រូវបានបង្កើតឡើងជាមួយនឹងដើមទុន ចុះបញ្ជីសរុបចំនួន ៧ លានដុល្លារអាមេរិក ។ បច្ចុប្បន្ន **ក្រុមហ៊ុន លី ហួរ អ៊ិន សួរេន ម.ក** បានត្រៀម ខ្លួនរួចជាស្រេចក្នុងការផ្តល់សេវាជូនអតិថិជនដោយមានរចនាសម្ព័ន្ធដឹកនាំរឹងមាំ និងបុគ្គលិកភាគច្រើន មានចំណេះដឹង និងបទពិសោធន៍ច្រើនឆ្នាំ ក្នុងវិស័យធានារ៉ាប់រងទូទៅក្នុងប្រទេសកម្ពុជា និងតំបន់អាស៊ី ។ ក្រុមហ៊ុនយើងខ្ញុំមានស្ថានភាពហិរញ្ញវត្ថុរឹងមាំ ដែលគាំទ្រដោយក្រុមហ៊ុនមេ ( **លី ហួរ គ្រុប** ) និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ដែលមានស្ថានភាពហិរញ្ញវត្ថុកម្រិត “A” ។

ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ស្មោះត្រង់ និងចាត់ទុកអតិថិជនជាដៃគូអាជីវកម្មរយៈពេលវែង និង ដោយសារមានចំណេះដឹង និងបទពិសោធន៍លើវិស័យធានារ៉ាប់រងទូទៅ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **ក្រុមហ៊ុន លី ហួរ អ៊ិនសួរេន ម.ក** នឹងដើរតួនាទីដ៏សំខាន់ក្នុងការបំពេញតម្រូវការអតិថិជន និង ចូលរួមអភិវឌ្ឍន៍វិស័យធានារ៉ាប់រងទូទៅក្នុងប្រទេសកម្ពុជា ។

ជាចុងក្រោយ **ក្រុមហ៊ុន លី ហួរ អ៊ិនសួរេន ម.ក** សូមស្វាគមន៍ លោក លោកស្រី ក្នុងការផ្តល់សេវា ការពារតាមតម្រូវការ និងជាដៃគូអាជីវកម្មរយៈពេលវែងជាមួយក្រុមហ៊ុនយើងខ្ញុំ ។

**ឧកញ៉ា លី ហួរ**
**ប្រធានក្រុមប្រឹក្សាភិបាល**




## ក្រុមហ៊ុនមេ និងបុត្រសម្ព័ន្ធ

**លី ហួរ គ្រុប** តាមរយៈក្រុមហ៊ុនជាបុត្រសម្ព័ន្ធរបស់ខ្លួនផ្តល់ជូនអតិថិជននូវសេវាកម្មឈានមុខគេ ជាច្រើន ដែលរួមមានសេវាកម្ម ផ្តល់ប្រាក់កម្ចី, ផ្ទេរប្រាក់, ប្តូរប្រាក់,ហាងបញ្ចាំ, ភតិសន្យាហិរញ្ញវត្ថុ, អភិវឌ្ឍលំនៅដ្ឋាន, និង ធានារ៉ាប់រងទូទៅ ។

**លី ហួរ គ្រុប** គឺជាក្រុមហ៊ុនមួយ នៅក្នុងប្រទេសកម្ពុជា តែងតែចាត់ទុកវិនិយោគិន និងអតិថិជនទាំងអស់ ជាដៃគូអាជីវកម្មយូរអង្វែង ស្របពេលដែលប្រកាន់ខ្ជាប់នូវគុណតម្លៃស្នូលដូចជា៖ សុចរិតភាព តម្លាភាព គណនេយ្យភាព កិច្ចសហប្រតិបត្តិការ និងឆ្លើយតបតាមម្រូវការរបស់អតិថិជន។

### ក្រុមហ៊ុនបុត្រសម្ព័ន្ធ

**១. លី ហួរ អ៊ិចឆេង ខូអិលធីឌី**
**២. លី ហួរ ផនសប ខូអិលធីឌី**
**៣. បុរី វិមានភ្នំពេញ**
**៤. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លីហួរ ភីអិលស៊ី**
**៥. ទេពី អាហ្គ្រោ វិនិយោគ ខូអិលធីឌី**
**៦. លី ហួរ លីស៊ីង ភីអិលស៊ី**
**៧. លី ហួរ ផេប្រូ ភីអិលស៊ី**
**៨. លី ហួរ អ៊ិនសួរេន ម.ក**




# អំពីក្រុមហ៊ុន លី ហួរ អ៊ិនសួរេន ម.ក

**ក្រុមហ៊ុន លី ហួរ អ៊ិនសួរេន ម.ក** ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ ២០១៧ ។ ដោយទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការអាជីវកម្មធានារ៉ាប់រងទូទៅ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៧ ដែលមានដើមទុនចុះបញ្ជីសរុប ចំនួន ៧ លានដុល្លារអាមេរិក និងបានចាប់ផ្តើមបើកដំណើរការជាផ្លូវការ នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨ ។

**លី ហួរ អ៊ិនសួរេន ម.ក** គឺជាក្រុមហ៊ុនគ្រប់គ្រងដោយភាគទុនិកសញ្ជាតិកម្ពុជា ។ ភាគទុនិក របស់ក្រុមហ៊ុនយើងខ្ញុំគឺជាពាណិជ្ជករសញ្ជាតិកម្ពុជា ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ និងទទួលស្គាល់នៅក្នុងប្រទេសកម្ពុជា ។ យើងជឿជាក់ថា ចំណុចដ៏សំខាន់ខាងក្រោមនេះ គឺជាចំណុចដ៏ជោគជ័យក្នុងការប្រកួតប្រជែងជាមួយដៃគូអាជីវកម្មក្នុងវិស័យធានារ៉ាប់រងទូទៅ ៖

- **ក្រុមហ៊ុនមេ លី ហួរ គ្រុប** ទទួលបានកេរ្តិ៍ឈ្មោះដ៏ល្បីល្បាញនៅក្នុងប្រទេសកម្ពុជា គឺដោយសារប្រកាន់ខ្ជាប់នូវ **ភាពស្មោះត្រង់** និង **សុចរិតភាព** ។
- ផ្តល់ទំនុកចិត្ត និងសុវត្ថិភាពជូនអតិថិជន តាមរយៈការផ្តល់ជូននូវកិច្ចសន្យាធានារ៉ាប់រងប្រកបដោយភាពច្នៃប្រឌិតច្បាស់លាស់ បុព្វលាភធានារ៉ាប់រងសមរម្យដើម្បីបំពេញតម្រូវការជូនអតិថិជន ។
- បុគ្គលិកប្រកបដោយភាពរួសរាយ រាក់ទាក់ និងឆ្លើយតបឆាប់រហ័សទៅនឹងតម្រូវការរបស់អតិថិជន ជាពិសេសសេវាកម្មដោះស្រាយសំណង ។
- គណៈគ្រប់គ្រងមានបទពិសោធន៍ក្នុងវិស័យធានារ៉ាប់រងទូទៅ ។
- ការប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការប្រាស្រ័យទាក់ទង ការទូទាត់សាច់ប្រាក់ ការទូទាត់សំណង និង ការផ្តល់សេវាកម្មតាមតម្រូវការផ្សេងទៀត ។
- ការគាំទ្រផ្នែកហិរញ្ញវត្ថុដ៏រឹងមាំដោយក្រុមហ៊ុនមេ និង ក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានស្ថានភាពហិរញ្ញវត្ថុកម្រិត “A”
- ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកទាំងអស់ ដើម្បីឲ្យពួកគេមានចំណេះដឹងគ្រប់គ្រាន់ និងលើកកំពស់ជំនាញវិជ្ជាជីវៈផ្ទាល់ខ្លួន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ទំនុកចិត្ត សុវត្ថិភាព

## ចក្ខុវិស័យ និងបេសកកម្ម

### ចក្ខុវិស័យ

**គឺជាក្រុមហ៊ុនធានារ៉ាប់រងទូទៅឈានមុខគេនៅក្នុងប្រទេសកម្ពុជា**

### បេសកកម្ម

**លី ហួរ អ៊ិនសួរេន ម.ក** បានប្តេជ្ញាចិត្តខ្ពស់ ដើម្បីក្លាយជាក្រុមហ៊ុនធានារ៉ាប់រង ឈានមុខគេនៅក្នុងប្រទេសកម្ពុជា តាមរយៈការអនុវត្តនូវគោលការណ៍ដូចខាងក្រោម៖

- ផ្តល់សេវាធានារ៉ាប់រងប្រកបដោយទំនុកចិត្ត និងសុវត្ថិភាពខ្ពស់
- ផ្តល់សេវាធានារ៉ាប់រងសមស្របទៅតាមតម្រូវការរបស់អតិថិជន
- ធនធានមនុស្សប្រកបដោយចំណេះដឹង និងបទពិសោធន៍លើវិស័យធានារ៉ាប់រង
- ផ្តល់ការប្រឹក្សាយោបល់លើវិស័យធានារ៉ាប់រងប្រកបដោយវិជ្ជាជីវៈ
- បុព្វលាភរ៉ាប់រងមានលក្ខណៈសមរម្យ និងភាពប្រកួតប្រជែងជាមួយដៃគូ
- សេវាដោះស្រាយសំណងឆាប់រហ័ស និងត្រឹមត្រូវទៅតាមគោលការណ៍កំណត់របស់ក្រុមហ៊ុន
- ប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិជ្ជាទំនើប ដើម្បីគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម





## ផលិតផល និងសេវាកម្ម

**លី ហួរ អ៊ិនសួរេន ម.ក** បានត្រៀមខ្លួនរួចជាស្រេចក្នុងការបម្រើអតិថិជនរបស់ខ្លួនជាមួយនឹងគណៈគ្រប់គ្រង និងបុគ្គលិក មានចំណេះដឹង និងបទពិសោធន៍លើវិស័យធានារ៉ាប់រងទូទៅក្នុងព្រះរាជាណាចក្រកម្ពុជានិងក្នុងតំបន់អាស៊ី ។ ក្រុមហ៊ុនផ្តល់ជូននូវផលិតផល សេវាធានារ៉ាប់រងទូទៅ ដែលត្រឹមត្រូវតាមច្បាប់ ដូចខាងក្រោម ៖

### ធានារ៉ាប់រងទ្រព្យសម្បត្តិ

- ធានារ៉ាប់រងអគ្គីភ័យ
- ធានារ៉ាប់រងគ្រប់ហានិភ័យនៃទ្រព្យសម្បត្តិ

### ធានារ៉ាប់រងវិស្វកម្ម

- ធានារ៉ាប់រងការដ្ឋានសាងសង់
- ធានារ៉ាប់រងការដំឡើងសម្ភារវិស្វកម្ម
- ធានារ៉ាប់រងគ្រឿងចក្រ និងគ្រឿងម៉ាស៊ីនក្នុងការដ្ឋានសាងសង់
- ធានារ៉ាប់រងការខូចខាតគ្រឿងម៉ាស៊ីន
- ធានារ៉ាប់រងឧបករណ៍អគ្គិសនី



## ការធានារ៉ាប់រងយានយន្ត

- ការធានារ៉ាប់រងយានយន្តឯកជន
- ការធានារ៉ាប់រងយានយន្តអាជីវកម្ម
- ការធានារ៉ាប់រងទោចក្រយានយន្ត

## ការធានារ៉ាប់រងអត្ថប្រយោជន៍និយោជិក

- ធានារ៉ាប់រងសុខភាព
- ធានារ៉ាប់រងគ្រោះថ្នាក់បុគ្គល

## ធានារ៉ាប់រងផ្សេង ៗ ទៀត

- ធានារ៉ាប់រងការទទួលខុសត្រូវជាសាធារណៈ
- ធានារ៉ាប់រងការទទួលខុសត្រូវភាគីតតិយជនទូទៅ
- ធានារ៉ាប់រងការទទួលខុសត្រូវលើផលិតផល
- ធានារ៉ាប់រងរូបិយវត្ថុ
- ធានារ៉ាប់រងអំពើចោរកម្ម
- ធានារ៉ាប់រងការក្លែងបន្លំរបស់និយោជិត
- ធានារ៉ាប់រងគ្រោះថ្នាក់ចំពោះកម្មករនិយោជិត
- ធានារ៉ាប់រងសំណង់វិជ្ជាជីវៈ
- ធានារ៉ាប់រងការដឹកជញ្ជូនទំនិញ



## ក្រុមហ៊ុនធានារ៉ាប់រងបន្ត

កិច្ចសន្យាធានារ៉ាប់រងទាំងអស់ ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រង **លី ហួរ អ៊ិនសួរេន ម.ក** គឺត្រូវបានធានារ៉ាប់រងបន្តដោយ ក្រុមហ៊ុនធានារ៉ាប់រងបន្ត ដែលមានស្ថានភាពហិរញ្ញវត្ថុកម្រិត “A” ។ ក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់យើង មានដូចខាងក្រោម៖

- ក្រុមហ៊ុនធានារ៉ាប់រងបន្ត “កម្ពុជា រី”
- General Insurance Corporation of India Labuan Branch “GIC Re”
- Hannover Ruck SE , Malaysia
- Sava Reinsurance Company Limited , Slovenia
- Santam Limited , South Africa “on Behalf of Munich Re”
- Asia Insurance Company Limited , Hong Kong
- National Reinsurance Corporation of the Philippines “NRCP”



## សេវាកម្មដោះស្រាយសំណង

ទិសដៅចម្បងរបស់យើង គឺក្លាយជាអ្នកផ្តល់សេវាដោះស្រាយសំណងដ៏ល្អបំផុតនៅក្នុងប្រទេសកម្ពុជា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាទំនើប ។

នៅពេលមានគ្រោះថ្នាក់កើតឡើង សូមទាក់ទងមកកាន់ទូរស័ព្ទប្រចាំការ ដោះស្រាយសំណង ២៤ ម៉ោងរបស់យើងខ្ញុំតាមរយៈលេខ **០៨១ ៦៦ ០០០០** បុគ្គលិកផ្នែកដោះស្រាយសំណងយើងខ្ញុំបានត្រៀមខ្លួន ក្នុងការឆ្លើយតបនិងដោះស្រាយចម្ងល់ជូនលោកអ្នក ២៤ ម៉ោង ។







## សម្រាប់ព័ត៌មានទូទៅ

សូមទំនាក់ទំនងមកលេខ: ០៨១ ៣៣ ០០០០
អាសយដ្ឋាន: ដីឡូត៍លេខ ២៤៣-២៤៤ អគារលេខ ១F ផ្លូវលេខ ៥៩៨
សង្កាត់ទួលសង្កែ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ។
អ៊ីមែល: info@lyhourinsurance.com
គេហទំព័រ: www.lyhourinsurance.com